# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ៤៧/១០-ម៉ារូ ឈុន

កាលបរិច្ឆេទនៃសេចក្តីសម្រេច : ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង ស៊ុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: អន ណាន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: ប៉ែន ប៊ុនឈា

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) ខប អិលធីឌី

អាសយដ្ឋាន : ភូមិត្រពាំងរាំចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៥០២ ៨៦៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក CHANG HAN CHANG នាយកក្រុមហ៊ុន

២- លោក យ៉ាំ ថៃសាន រដ្ឋបាលក្រុមហ៊ុន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ

- សហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ នៃរោងចក្រស្បែកជើង ម៉ារូ ឈុន

អាសយដ្ឋាន : ភូមិត្រពាំងរាំចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៥៣៣ ៨៣២ លេខទូរសារ : គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

១- លោក ឈុំ វាសនា ប្រធានសហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ

២- លោក គង់ សុភ័ក្ត្រ ប្រធានសហជីពដើម្បីកម្មករ នៃរោងចក្រ ម៉ារូឈុន

៣- លោក មាស តូក អនុប្រធានសហជីពដើម្បីកម្មករ នៃរោងចក្រ ម៉ារូឈុន

៤- លោក ស៊ុន សាត លេខាធិការសហជីពដើម្បីកម្មករ នៃរោងចក្រ ម៉ារូឈុន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកលោក គង់ សុភ័ក្ត្រ លោក មាស តូក លោក ស៊ុន សាត ជាថ្នាក់ដឹកនាំសហជីពកម្ពុជា ដើម្បីសិទ្ធិកម្មករនៃក្រុមហ៊ុនស្បែកជើង ម៉ារូឈុន ចូលធ្វើការវិញ ព្រោះថាពួកគាត់បានធ្វើការអស់រយៈពេល ០៥ ខែ ហើយ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកអ្នកទាំងបីឱ្យចូលធ្វើការវិញបានឡើយ ព្រោះពួកគាត់ស្ថិតក្នុងការសាកល្បងការងារនៅឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៣៨៣ ក.ប./អក/វ.ក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល)។

THE ARBITRATION COUNCIL

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់មក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាចុងក្រោយ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០៩ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៣៨៣ ក.ប./អក/វក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីសហជីពដើម្បីកម្មករប្រចាំរោងចក្រ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាន នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ប៉ុន្តែ ជាលទ្ធផល ចំណុចវិវាទនេះមិនត្រូវបានសះជានឹងគ្នាទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា និងដោះស្រាយដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) ខបអិលធីឌី លេខ ១០៦១ ពណ.ចបព ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។

២- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) ខប អិលធីឌី លេខ DLT 030193.2010 ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០។

៣- លក្ខន្តិកៈរបស់ក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) ខប អិលធីឌី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០។

៤- លិខិតជូនដំណឹងរបស់ប្រធានសហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ គោរពជូន លោកនាយកក្រុមហ៊ុនស្បែកជើង ម៉ារូឈុន (ខេមបូឌា) ស្តីពីការបង្កើតសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករនៃរោងចក្រ។

THE ARBITRATION COUNCIL

ស្បែកជើង ម៉ារូឈុន (ខេមបូឌា) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០។

៥- របាយការណ៍ស្តីពីការផ្ញើសំបុត្រឱ្យផ្នែករដ្ឋបាល ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០។

៦- ប័ណ្ណប្រកាសលាលែង, កិច្ចសន្យារបស់ឈ្មោះ ស៊ុន សាត, មាស តូក និង គង់ សុភ័ក្រ្ត។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតជូនដំណឹងរបស់ប្រធានសហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ គោរពជូន លោកនាយកក្រុមហ៊ុនស្បែកជើង ម៉ារូឈុន (ខេមបូឌា) ស្តីពីការបង្កើតសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករនៃរោងចក្រស្បែកជើង ម៉ារូឈុន (ខេមបូឌា) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០។

២- ប័ណ្ណសំគាល់ខ្លួនរបស់ឈ្មោះ ស៊ុន សាត,។

៣- ប័ណ្ណសំគាល់ខ្លួនបណ្តោះអាសន្នរបស់ឈ្មោះ ស៊ុន សាត, គង់ សុភ័ក្រ្ត និង មាស តូក។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) លេខ ៣៨៣ ក.ប/អក/វ.ក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ម៉ារូឈុន (ខេមបូឌា) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៤៧ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ក្រុមហ៊ុនស្បែកជើង ម៉ារូ ឈុន បានចាប់ដំណើរការនៅខែមីនា ឆ្នាំ២០១០។ បច្ចុប្បន្ននេះ ក្រុមហ៊ុនមានជួល កម្មករនិយោជិតសរុបចំនួន ១២០០ នាក់។

THE ARBITRATION COUNCIL

- នៅក្នុងក្រុមហ៊ុនមានសហជីពពីរ គឺសហជីពខ្មែរ និងសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ។ សហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ ភាគីសហជីពបានបញ្ជាក់ថា សហជីពបានរៀបចំបោះឆ្នោតនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ វេលាម៉ោង ០៤:៣០ នាទីល្ងាច នៅទីស្នាក់ការសហព័ន្ធ ដែលមានកម្មករនិយោជិតប្រមាណ ២០ នាក់ ចូលរួមបោះឆ្នោត។ នៅក្នុងលិខិតរបស់សហព័ន្ធសហជីពជូនដំណឹងទៅក្រុមហ៊ុន ស្តីពីការបង្កើតសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករនៃរោងចក្រស្បែកជើង ម៉ារូ ឈុន ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ បានបញ្ជាក់ថា ថ្នាក់ទទួលខុសត្រូវការងារគ្រប់គ្រង រួមមាន លោក គង់ សុភ័ក្រ្ត ជាប្រធានសហជីព លោក មាស តូក អនុប្រធាន សហជីព និងថ្នាក់ទទួលខុសត្រូវរដ្ឋបាលមាន លោក ស៊ុន សាត លេខាធិការសហជីព ដោយមិនបានបញ្ជាក់ថា លោក គង់ សុភ័ក្រ្ត ទទួលបានសម្លេងប៉ុន្មាន ជាប់ជាប្រធាន លោក មាស តូក ទទួលបានសម្លេងប៉ុន្មាន ជាប់ជាអនុប្រធានសហជីព និងលោក ស៊ុន សាត ទទួលបានសម្លេងប៉ុន្មាន ជាប់ជាលេខាធិការសហជីព។ បន្ទាប់មក នៅក្នុងសវនាការ ភាគីសហជីពបែរជាបញ្ជាក់ថា កម្មករនិយោជិតមិនបានបោះឆ្នោតទេ គឺលោក គង់ សុភ័ក្រ្ត ត្រូវបានចាត់តាំងជាប្រធានសហជីព លោក មាស តូក ត្រូវបានចាត់តាំងជាអនុប្រធានសហជីព និងលោក ស៊ុន សាត ត្រូវបានចាត់តាំងជាលេខាធិការសហជីព ហើយសហជីមិនទាន់បានដាក់ពាក្យសុំចុះបញ្ជិកាទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ។

ចំណុចវិវាទ : **ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ទទួលយកលោក គង់ សុភ័ក្រ្ត លោក មាស តូក លោក ស៊ុន សាត ជាថ្នាក់ដឹកនាំសហជីពកម្ពុជា ដើម្បីសិទ្ធិកម្មករនៃក្រុមហ៊ុនស្បែកជើង ម៉ារូ ឈុន ឱ្យចូលធ្វើការវិញ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់ទាមទារឱ្យក្រុមហ៊ុនទទួលយក លោក គង់ សុភ័ក្រ លោក មាស តូក និងលោក ស៊ុន សាត ឱ្យចូលធ្វើការវិញ ដោយហេតុថា ក្រុមហ៊ុនមានការរើសអើងសហជីព ពីព្រោះ ពួកគាត់ទាំងបីនាក់ជាថ្នាក់ដឹកនាំសហជីព។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិត និងភាគីនិយោជក បានបញ្ជាក់ថា លោក គង់ សុភ័ក្រ្ត និងលោក មាស តូក ជាជាងភ្លើង និង លោក ស៊ុន សាត ជាជាងម៉ាស៊ីន បានចុះកិច្ចសន្យាការងារសាកល្បង ពីមួយខែ ដល់បីខែ ជាមួយភាគីនិយោជកនៃក្រុមហ៊ុន ម៉ារូ ឈុន នៅថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១០។
- ភាគីសហជីពបានបញ្ជាក់ថា ក្រោយពីការចាត់តាំងថ្នាក់ដឹកនាំសហជីពរួចមក នៅដែលដែលនេះ សហជីពមិនបានជូនដំណឹងទៅក្រុមហ៊ុនអំពីសមាសភាពថ្នាក់ដឹកនាំសហជីពទេ។ ភាគីសហជីពបានបញ្ជាក់ថា ដោយសារពួកគាត់ជាប់រវល់ ទើបពួកគាត់មិនយកលិខិតជូនដំណឹងនេះ ជូនទៅក្រុមហ៊ុនទេ។

គឺទុករហូតដល់ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៤:០០ នាទី រសៀល ទើបយកទៅជូនក្រុមហ៊ុន។ ភាគីក្រុមហ៊ុនមិនបានជំទាស់នឹងការលើកឡើងនេះទេ។

- ក្រុមហ៊ុនបានបញ្ឈប់ លោក គង់ សុភ័ក្រ្ត និងលោក មាស តូក ពីការងារ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៧:២០ នាទីព្រឹក និងបញ្ឈប់លោក ស៊ុន សាត ពីការងារ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោងប្រហែល ៩:០០ ព្រឹក។ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនបានបញ្ឈប់ពួកគាត់ទាំងបីនាក់ពីការងារ បន្ទាប់ពីរដ្ឋបាល ប្រធានផ្នែក អ្នកចាត់ការទូទៅ បានប្រជុំពិភាក្សាវាយតម្លៃការងាររបស់ពួកគាត់ នៅថ្ងៃទី០៤ ខែឧសភាព ឆ្នាំ២០១០ ឃើញថា ពួកគាត់ទាំងបីនាក់ មិនបានជាប់ការងារសាកល្បងទេ។ មូលហេតុដែលក្រុមហ៊ុនបញ្ឈប់ ដោយហេតុថា ពួកគាត់ធ្វើការមិនល្អ គឺមិនពាក់ព័ន្ធនឹងការរើសអើងសហជីពទេ ពីព្រោះក្រុមហ៊ុនបានសម្រេចបញ្ឈប់ពួកគាត់មុនពេលក្រុមហ៊ុនទទួលបានលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកសហជីពទៅទៀត។ មូលហេតុដែលក្រុមហ៊ុនបញ្ឈប់ លោក ស៊ុន សាត នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ ក៏ដូចគ្នាទៅនឹងមូលហេតុដែលបញ្ឈប់លោក គង់ សុភ័ក្រ្ត និងលោក មាស តូក ដែរ គឺលោក ស៊ុន សាត មិនជាប់ការងារសាកល្បង។ ការដែលនិយោជកមិនទាន់បានបញ្ឈប់លោក ស៊ុន សាត នៅថ្ងៃជាមួយគ្នា គឺព្រោះភាគីនិយោជកមិនអាចរកលោក ស៊ុន សាត ឃើញ ទើបបញ្ឈប់គាត់នៅថ្ងៃបន្ទាប់ គឺនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់បន្ថែមថា នៅក្នុងកំឡុងពេលដែលក្រុមហ៊ុនបញ្ឈប់ពួកគាត់ទាំងបីនាក់នេះ ក្រុមហ៊ុនក៏បានបញ្ឈប់កម្មករនិយោជិតចំនួនពីរ ឬ បីនាក់ ផ្សេងទៀតដែរ។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីកម្មករនិយោជិតបានលើករំលេះអំណាងថា លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត បានចូលធ្វើការនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ ដែលមានរយៈពេលលើសពី ២ ខែហើយ ក្រុមហ៊ុនមិនអាចបញ្ឈប់ពួកគាត់ទាំងបីបានទេ ដោយសារពួកគាត់លែងស្ថិតក្នុងការងារសាកល្បងទៀតទេ ពីព្រោះ ពួកគាត់ជាកម្មករឯកទេស យោងតាមមាត្រា ៦៨ នៃច្បាប់ស្តីពីការងាររយៈពេលសាកល្បងការងារមិនត្រូវហួសពីពីរខែទេ។
- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកលោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ចូលធ្វើការវិញ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ទទួលយកលោក គង់ សុភ័ក្ត្រ លោក មាស តូក លោក ស៊ុន សាត ជាថ្នាក់ដឹកនាំសហជីពកម្ពុជា ដើម្បីសិទ្ធិកម្មករ នៃក្រុមហ៊ុនស្បែកជើង ម៉ារូ ឈុន ឱ្យចូលធ្វើការវិញ**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានធ្វើការចោទប្រកាន់ថា ក្រុមហ៊ុនបញ្ឈប់លោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត ពីការងារ ដោយហេតុថា ក្រុមហ៊ុនមានការរើសអើងសហជីព ពីព្រោះពួកគាត់ទាំងបីនាក់ជាថ្នាក់ដឹកនាំសហជីព។ ចំណែកឯភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនបានបញ្ឈប់ពួកគាត់ទាំងបីនាក់នេះ ពីព្រោះក្រុមហ៊ុនបានវាយតម្លៃការងាររបស់ពួកគាត់មិនបានជាប់ការងារសាកល្បងទេ ពីព្រោះពួកគាត់ទាំងបីនាក់ធ្វើការមិនល្អ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើលោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត មានប្រភេទកិច្ចសន្យាការងារអ្វី? តើលោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត ទទួលបានការការពារពិសេស ពីការបញ្ឈប់ដែរ ឬទេ? តើក្រុមហ៊ុនបញ្ឈប់ លោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត មានការរើសអើងសហជីពមែនដែរ ឬទេ? និងតើក្រុមហ៊ុនត្រូវទទួលយក លោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត ឱ្យចូលធ្វើការវិញដែរ ឬទេ?

<u>តើលោក គង់ សុភ័ក្ត្រ លោក មាស តូក និងលោក ស៊ុន សាត មានប្រភេទកិច្ចសន្យាការងារអ្វី?</u>

មាត្រា ៦៨ នៃច្បាប់ស្តីពីការងារចែងថា "*ការចុះកិច្ចសន្យាសាកល្បង មិនអាចមានថេរវេលាលើសកាលបរិច្ឆេទជាចាំបាច់សម្រាប់ឱ្យនិយោជក វិនិច្ឆ័យវិជ្ជាជីវៈ នៃកម្មករនិយោជិត ហើយនិងសម្រាប់កម្មករនិយោជិតស្គាល់យ៉ាងជាក់ច្បាស់នូវលក្ខខណ្ឌនៃការងារ ដែលគេផ្តល់ឱ្យនោះឡើយ។ ទោះបីយ៉ាងណាក៏ដោយ ក៏ការចុះកិច្ចសន្យាសាកល្បងការងារ មិនអាចមានថេរវេលាលើសពីបីខែទេ ចំពោះនិយោជិតពីរខែ ចំពោះកម្មករឯកទេស និងមួយខែចំពោះកម្មករធម្មតា ។*"

យោងតាមមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រយៈពេលសាកល្បងរបស់កម្មករនិយោជិតឯកទេស គឺមិនអាចលើសថិរវេលាពីរខែទេ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីក ស៊ូ ចំណុចវិវាទទី១ "*ការងារជាជាងជួសជុលម៉ាស៊ីនដេរ ដែលតម្រូវឱ្យមានជំនាញឯកទេស ដូចជាជួសជុលម៉ាស៊ីនដេរ គឺជាការងាររបស់កម្មករឯកទេស។*" ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ៦២/០៦-ឃ្វីក ស៊ូ នេះដែរ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ថា ការងារជាជាងភ្លើង ក៏តម្រូវឱ្យមានឯកទេសពិសេសខាងជាងភ្លើងដែរ។

ជារួមមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តើលោក គង់ សុភ័ក្រ្ត លោក មាស តូក ជាជាងភ្លើង និងលោក ស៊ុន សាត ជាជាងម៉ាស៊ីន គឺជាកម្មករនិយោជិតឯកទេស ដែលត្រូវមានថិរវេលាការងារសាកល្បងមិនលើសពី ២ ពីរខែទេ។

យោងតាមមាត្រា ៦៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ " *នៅពេលចុះហត្ថលេខាលើកិច្ចសន្យាការងារដែលធ្វើឡើងដោយការព្រមព្រៀងគ្នាដោយមានកំណត់ថិរវេលាពិតប្រាកដ ត្រូវតែមានថែងកាលបរិច្ឆេទច្បាស់លាស់នៃការចាប់ផ្តើម និងបញ្ចប់កិច្ចសន្យានោះ។* " ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាមានកំណត់ថិរវេលា ជាកិច្ចសន្យាដែលមានកំណត់ថិរវេលាចាប់ផ្តើម និងថិរវេលាបញ្ចប់កិច្ចសន្យានេះច្បាស់លាស់។

ក្នុងករណីណោះ លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត បានចុះកិច្ចសន្យាការងារសាកល្បងជាមួយនឹងនិយោជក មានថិរវេលាពីមួយខែ ដល់បីខែ ពោលគឺមានថិរវេលានៃការចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់។ ពួកគាត់ទាំងបីនាក់នេះ បានផុតរយៈពេលការងារសាកល្បង ក្នុងនាមជាកម្មករឯកទេសរួចហើយ ពោលគឺពួកគាត់បានធ្វើការក្នុងថិរវេលាលើសរយៈពេលពីរខែ ដែលជារយៈពេលសាកល្បងអតិបរមាកំណត់សម្រាប់កម្មករនិយោជិតឯកទេស។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត មានប្រភេទកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា។

<u>តើលោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ទទួលបានការការពារពិសេសពីការបញ្ឈប់ដែរ ឬទេ?</u>

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ជាថ្នាក់ដឹកនាំសហជីព តាមរយៈការចាត់តាំង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើពួកគាត់ទាំងបីនាក់ ទទួលបានការការពារពិសេសពីការបញ្ឈប់ ដែរ ឬទេ?

ប្រការ៣ កថាខណ្ឌទី២ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា " *លក្ខន្តិកៈសហជីព ត្រូវកំណត់លក្ខខណ្ឌសំរាប់ជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនតាមរយៈការបោះឆ្នោតជាសម្ងាត់... ។* "

ប្រការ៣ កថាខណ្ឌទី៣ នៃប្រកាសលេខ ៣០៥ សកបយ ដដែល ចែងថា " *កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារ ចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ។ ការការពារនេះមានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត។ សហជីពត្រូវជូនដំណឹង ទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាពានការ។ និយោជកត្រូវអនុវត្តបទបញ្ញត្តិនេះនៅរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព។* "

THE ARBITRATION COUNCIL

យោងតាម ប្រការ ៣ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃប្រកាសលេខ ៣០៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបោះឆ្នោតជាសម្ងាត់ត្រូវធ្វើឡើងនៅពេលបង្កើតសហជីព ហើយការការពារពីការបញ្ឈប់ពីការងារ គឺអាចត្រូវបានផ្តល់ជូនដល់បេក្ខជនទាំងអស់ ដែលបានឈរឈ្មោះសម្រាប់ការបោះឆ្នោតជាថ្នាក់ដឹកនាំសហជីពទាំងមុន និងក្រោយការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ។

បន្ថែមពីនេះ ប្រការ ៤ កថាខណ្ឌទី១ នៃប្រកាសលេខ ៣០៥ ខាងលើ ចែងថា" *ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជិកាសហជីព កម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្ត ចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ត្រូវបានការការពារ ដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។*"

ប្រការ ៤ កថាខណ្ឌទី២ នៃប្រកាសលេខ ៣០៥ ដដែល ចែងថា " *ផុតរយៈពេលកំណត់ក្នុងកថាខណ្ឌខាងលើ ការការពារនេះ ត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ០៣ នាក់ ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង ២៨៣ នៃច្បាប់ស្តីពីការងារ ។*"

ផ្អែកលើប្រការ ៤ កថាខណ្ឌទី១ និងទី២ នៃប្រកាស ៣០៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការពារពីការបញ្ឈប់ពីការងារនេះ គឺការពារដល់សមាជិកស្ថាបនិក ក្នុងពេលដាក់ពាក្យសុំចុះបញ្ជិកា និងចំពោះអ្នកដឹកនាំសហជីព ០៣ នាក់ បន្ទាប់ពីផុតរយៈពេលនៃការការពារសមាជិកស្ថាបនិក ។

តាមអង្គហេតុ លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ត្រូវបានចាត់តាំងជាថ្នាក់ដឹកនាំសហជីពផ្ទុយទៅនឹងច្បាប់ស្តីពីការ ពីព្រោះពួកគាត់មិនបានជ្រើសរើសតាមរយៈការបោះឆ្នោតនោះទេ ហើយសហជីពក៏មិនទាន់ដាក់ពាក្យសុំចុះបញ្ជិកាផងដែរ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត មិនស្ថិតនៅក្នុងចំណោតថ្នាក់នៃកម្មករនិយោជិតដែលទទួលបានការការពារ ពីការបញ្ឈប់ពីការងារទេ ។

<u>តើក្រុមហ៊ុនបញ្ឈប់ លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត មានការរើសអើងសហជីព មែន ដែរ ឬទេ?</u>

មាត្រា ១២ នៃច្បាប់ស្តីពីការងារចែងថា " *..... គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីសម្រេចអំពី.......ការជួល ការកំណត់ និងការបែងចែកការងារ.....*" ។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា " *ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចក្នុងការ... បែងចែកការងារ....*" ។

THE ARBITRATION COUNCIL

តាមខ្លឹមសារមាត្រា១២ និងមាត្រា ២៧៩ នៃច្បាប់ស្តីពីការងារ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមិនត្រូវយកមូលហេតុនៃការធ្វើសកម្មភាពសហជីព ឬយកការចូលជាសមាជិកសហជីពរបស់កម្មករនិយោជិត ជាមូលដ្ឋាននៅក្នុងការជួលកម្មករនិយោជិតនោះទេ។

ប៉ុន្តែ ជាទូទៅ នៅក្នុងករណីការទាមទារ ដែលពាក់ព័ន្ធនឹងការរើសអើងសហជីព ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងថា ភាគីនិយោជកមានការរើសអើងសហជីព (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ៥៦/០៩-សាន់តិច ហេតុផលនៃចំណុចវិវាទទី២ និងលេខ ៦១/០៩-ស៊ីន ទ្រី ហេតុផលនៃចំណុចវិវាទទី១*)។

ផ្អែកលើអង្គហេតុខាងលើ ភាគីកម្មករនិយោជិតបានធ្វើការចោទប្រកាន់ថា ក្រុមហ៊ុនបានធ្វើការបញ្ឈប់លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ពីការងារ ដោយសារមានការរើសអើងសហជីព ពីព្រោះពួកគាត់ជាថ្នាក់ដឹកនាំសហជីព។ ជាក់ស្តែង ភាគីនិយោជកបានធ្វើការបញ្ឈប់លោក គង់ សុភ័ក្រ្ត និងលោក មាស តូក ពីការងារ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៧:២០ នាទីព្រឹក និងបញ្ឈប់លោក ស៊ុន សាត ពីការងារ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោងប្រហែល ៩:០០ ព្រឹក។ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនបញ្ឈប់ពួកគាត់ទាំងបីនាក់ពីការងារ បន្ទាប់ពីរដ្ឋបាល ប្រធានផ្នែក អ្នកចាត់ការទូទៅ បានប្រជុំពិភាក្សាវាយតម្លៃការងាររបស់ពួកគាត់ នៅថ្ងៃទី០៤ ខែឧសភាព ឆ្នាំ២០១០ ឃើញថា ពួកគាត់ទាំងបីនាក់ មិនបានជាប់ការងារសាកល្បងទេ។ ភាគីកម្មករនិយោជិតបានជូនដំណឹងអំពីការជ្រើសរើសថ្នាក់ដឹកនាំសហជីព នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៤:០០ រសៀល គឺក្រោយពេលដែលនិយោជកបញ្ឈប់កម្មករនិយោជិតពីររូប គឺលោក គង់ សុភ័ក្រ្ត និងលោក មាស តូក។ រីឯ កម្មករនិយោជិតមួយរូបទៀតគឺ លោក ស៊ុន សាត ដែលត្រូវបានបញ្ឈប់នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ មួយថ្ងៃក្រោយការជូនដំណឹងពីសមាសភាពថ្នាក់ដឹកនាំសហជីពនោះ គឺនិយោជកបានអះអាងថាមិនអាចរកកម្មករនិយោជិតរូបនេះឃើញ ដើម្បីបញ្ឈប់។ ភាគីនិយោជកបានធ្វើការវាយតម្លៃឃើញថា អ្នកទាំងបីមិនជាប់ការងារសាកល្បងរួចទៅហើយ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅពេលដែលនិយោជកបញ្ឈប់កម្មករនិយោជិតទាំងបីរូបនេះ និយោជកក៏បានបញ្ឈប់កម្មករនិយោជិតពីរ ឬបីនាក់ផ្សេងទៀត ដែលមិនជាប់ការងារសាកល្បងផងដែរ។ ភាគីកម្មករនិយោជិតមិនបានបង្ហាញហេតុផលបន្ថែមផ្សេងទៀតដើម្បីបញ្ជាក់ថា និយោជកពិតជាបានរើសអើងសហជីពនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា ក្រុមហ៊ុនបញ្ឈប់លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ពីការងារនេះ មិនពាក់ព័ន្ធនឹងការរើសអើងសហជីពទេ។

THE ARBITRATION COUNCIL

តើក្រុមហ៊ុនត្រូវទទួលយក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ឱ្យចូលធ្វើការវិញ ដែរ ឬទេ?

ដូចបានបកស្រាយខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត មានប្រភេទកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា ពីព្រោះ ពួកគាត់បានផុតរយៈពេលការងារសាកល្បង ក្នុងនាមជាកម្មករឯកទេសរួចហើយ ពោលគឺពួកគាត់បានធ្វើការក្នុងថិរវេលាលើសរយៈពេលពីរខែ ដែលជារយៈពេលសាកល្បងអតិបរមាកំណត់សម្រាប់កម្មករនិយោជិតឯកទេស។

យោងតាមមាត្រា ៧៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ ចែងថា " *កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់ ។.....*"

មាត្រា ៧៣ កថាខណ្ឌទី២ នៃច្បាប់ការងារចែងថា " *បើគ្មានការព្រមព្រៀងរបស់ភាគីទាំងសងខាងទេ កិច្ចសន្យាដែលមានកំណត់ថិរវេលាពិតប្រាកដ អាចរំលាយមុនកាលកំណត់បានតែក្នុងករណីដែលមានកំហុសធ្ងន់ ឬករណីប្រធានស័ក្តិ ។*"

មាត្រា ៧៣ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការងារចែងថា " *ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់និយោជកតែឯកឯងមុនកាលកំណត់ក្រៅពីមូលហេតុដែលមានចែងក្នុងកថាខ័ណ្ឌទី១ និងទី២ នៃមាត្រានេះ បើកសិទ្ធិអោយកម្មករនិយោជិតទទួលជំងឺចិត្តដែលមានចំនួនយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវបានទទួលរហូតដល់ពេលចប់កិច្ចសន្យា ។*" តាមរយៈអត្ថន័យនៃមាត្រា ៧៣ កថាខណ្ឌទី១ ទី២ និងទី៣ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើគ្មានការព្រមព្រៀង ពីគូភាគីនៃកិច្ចសន្យាក្នុងការរំលាយកិច្ចសន្យាមុនដល់កាលកំណត់ទេនោះ ភាគីកម្មករនិយោជិតដែលត្រូវបានភាគីនិយោជកបញ្ឈប់ពីការងារ ដោយឯកឯង ក្រៅពីមូលហេតុកំហុសធ្ងន់ ឬករណីប្រធានស័ក្តិមានសិទ្ធិទទួលបាននូវសំណងជម្ងឺចិត្ត យ៉ាងហោចណាស់ស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវបានទទួល រហូតដល់ពេលចប់កិច្ចសន្យា។

តាមអង្គហេតុ និយោជកបានធ្វើការរំលាយកិច្ចសន្យាការងារ លោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ដែលនៅក្រោមកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ធ្វើឡើងដោយភាគីទាំងពីរ មុនដល់កាលកំណត់ ក្រៅពីមូលហេតុកំហុសធ្ងន់ ឬករណីប្រធានស័ក្តិ។ ដូចនេះ ផ្អែកលើមាត្រា ៧៣ កថាខណ្ឌទី១ ទី២ និងទី៣ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមានសិទ្ធិទទួលបាននូវសំណងជម្ងឺចិត្ត ដូចមានចែងក្នុងមាត្រា ៧៣ នេះ។ ប៉ុន្តែ នៅក្នុងសវនាការកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលយកពួកគាត់ឱ្យចូលធ្វើការវិញ ភាគីកម្មករនិយោជិតមិនបានទាមទារឱ្យនិយោជកផ្តល់សំណងជម្ងឺចិត្តនោះទេ។

ដូច្នេះ ជាសរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុន ទទួលយកលោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ចូលធ្វើការវិញ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនទទួលយកលោក គង់ សុភ័ក្រ្ត លោក មាស តូក និងលោក ស៊ុន សាត ចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :
ឈ្មោះ : អ៊ុំ សុទ្ធី
ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :
ឈ្មោះ : អន ណាន
ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :
ឈ្មោះ : ម៉ែន ម៉ុនីឃាវ
ហត្ថលេខា: ----------------------------------------

THE ARBITRATION COUNCIL